# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ក្រោមប្រធានបទ គាថាមួយបទពោលថា អ្នកឈ្នះតែងជួបប្រទះនូវពៀរ អ្នកចាញ់តែងដេកកើតទុក្ខ អ្នកលះការឈ្នះការចាញ់បានហើយ គឺជាអ្នកស្ងប់តែងដេកនៅជាសុខ ។

**Website: www.hoksavann.org**



ថ្ងៃទី១១ ឧសភា ២០១០

ពាក្យថា «អ្នកឈ្នះតែងជួបប្រទះនូវពៀរ អ្នកចាញ់តែងដេកកើតទុក្ខ អ្នកលះការឈ្នះការចាញ់បានហើយ គឺជាអ្នកស្ងប់តែងដេកនៅជាសុខ» នេះ ចេញមកពីបាលីជាគាថាថា ៖ ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ ។

ពាក្យថា «អ្នកឈ្នះតែងជួបប្រទះនូវពៀរ» មានន័យសេចក្តីថា ជំនះណាមួយកើតអំពីអំពើឈ្លានពាន អំពើកេងប្រវ័ញ្ច អំពើរំលោភគំរាមកំហែង អំពើទុច្ចរិត ដែលចាត់ទុកជាអំពើរំលោភសិទ្ធិមនុស្ស អំពើនេះធ្វើឲ្យគេមានទុក្ខ ជំនះគ្មានយុត្តិធម៌នេះ ឱកាសល្អណាមួយ អ្នកចាញ់នឹងធ្វើការសងសឹកវិញ ជាជំនះពុំស្ថិតស្ថេរ តែងមានសត្រូវចាំបៀតបៀនជានិច្ច ។ ផ្ទុយពីពាក្យខាងលើនេះ បើជំនះណាកើតឡើងប្រាសចាកការបៀតបៀន ជាជំនះត្រឹមត្រូវតាមផ្លូវធម៌និងមិនខុសនឹងច្បាប់រដ្ឋ ជាជំនះពុំមានពៀរនឹងអ្នកដទៃឡើយ ។ បើប្រជាពលរដ្ឋគ្រប់ឋាន:សុខចិត្តគោរពច្បាប់ទាំងអស់គ្នា បើមានជនណាមួយពុំគោរពច្បាប់ អ្នកឈ្នះអាចមានបញ្ហាជាមួយអ្នកចាញ់ ។

ពាក្យថា «អ្នកចាញ់តែងដេកកើតទុក្ខ» មានន័យសេចក្តីថា អ្នកចាញ់ដោយលេងល្បែងស៊ីសងផ្សេងៗក្តី ការចាញ់ដោយជម្លោះផ្សេងៗក្តី តែងតែដេកកើតទុក្ខ ។ តាមធម្មតាទឹកចិត្តរបស់មនុស្សសាមញ្ញ កាលណាចាញ់ទោះបីចាញ់ដោយយុត្តិធម៌ក្តី អយុត្តិធម៌ក្តី តែងកើតទុក្ខព្រោះពុំសំរេចតាមគោលបំណង ។ បើមនុស្សគោរពច្បាប់ បើចាញ់ប្រកបដោយយុត្តិធម៌ សុខចិត្តទទួលស្គាល់នូវលទ្ធផលនៃការចាញ់នោះ ។ ប៉ុន្តែបើចាញ់ប្រកបដោយអយុត្តិធម៌វិញ មិនសុខចិត្តតែងតែរកមធ្យោបាយដើម្បីយកជ័យជំនះវិញ ។

ពាក្យថា «អ្នកលះការឈ្នះការចាញ់បានហើយ គឺជាអ្នកស្ងប់រមែងដេកនៅជាសុខ» តាមផ្លូវធម៌មានអត្ថន័យថា ថ្នាក់ព្រះអរហន្តទាំងឡាយមានព្រះពុទ្ធជាដើម ឃើញទោសនៃសង្ខារទាំងឡាយមានខន្ធប្រាំជាដើម ជាទុក្ខ ជាសភាវធម៌កើតឡើងហើយ តែងតែរលត់ទៅវិញជាធម្មតា ។ ដោយឃើញការពិតនេះ ធ្វើឲ្យព្រះទ័យព្រះអង្គស្ងប់ មិនជាប់ជំពាក់ដោយចំណង់អ្វីឡើយ ។ អ្នកឈ្នះការចាញ់អ្នកដទៃជាបញ្ហារបស់មនុស្សសាមញ្ញ ចំពោះព្រះអរិយបុគ្គលទាំងឡាយមានព្រះពុទ្ធជាដើម ព្រះអង្គឈ្នះកិលេសតណ្ហាដែលស្ថិតក្នុងព្រះទ័យព្រះអង្គវិញទេ ។ ការឈ្នះនូវមារមានកិលេសមារជាដើម ជាជំនះពិតប្រាកដមិនត្រឡប់ចាញ់វិញឡើយ ។ ជាជំនះធ្វើឲ្យព្រះអរហន្តគង់នៅជាសុខក្នុងជីវិតបច្ចុប្បន្ន នៅពេលដែលលោកពុំទាន់រំលត់ខន្ធបរិនិព្វាន ។ សង្គមមនុស្សដែលពុំបានអប់រំចិត្តតាមផ្លូវព្រះធម៌ បើគិតពីរឿងមារ ពុំបានគិតពីមារដែលស្ថិតនៅក្នុងចិត្តរបស់ខ្លួនឡើយ តែងតែគិតពីមារថាមកអំពីអ្នកដទៃបង្កើតឲ្យមានឡើង ។ សេចក្តីពិត តាមព្រះពុទ្ធសាសនា មុននឹងមារខាងក្រៅចូលមកបាន ដោយសារមារខាងក្នុងបើកដៃ ។ បានសេចក្តីថា បើចិត្តសៅហ្មងហើយ អកុសលទាំងឡាយក៏កើតមាន ហើយវិបាករបស់អកុសលក៏កើតឡើង កើតបានជាទុក្ខវេទនាទៅតាមអកុសលកម្ម ។ បើគេមិនបានពិចារណានូវមារដែលស្ថិតនៅក្នុងចិត្តរបស់ខ្លួនឲ្យបានច្បាស់លាស់ជាមុនទេ គេតែងតែបន្ទោសអ្នកដទៃ នាំឲ្យបង្កើតជាជម្លោះទាស់ទែងខ្វែងគំនិតគ្នាពាសពេញពិភពលោក ចងពៀរវេរានឹងគ្នារកទីបំផុតគ្មានរហូតហ៊ានប្រហារជីវិតអ្នកដទៃដោយគ្មានធម៌មេត្តា ។ ការលះបង់បាននូវអវិជ្ជា តណ្ហា ដែលជាឫសគល់នៃការចង់ឈ្នះចាញ់គ្នាបានហើយ ជាបុគ្គលស្ងប់មិនធ្វើនូវបាបទាំងឡាយ នាំឲ្យបុគ្គលបាននូវសេចក្តីសុខ ដូចពុទ្ធភាសិតថា សេចក្តីសុខអ្នកដទៃប្រាសចាកសេចក្តីស្ងប់ពុំមានឡើយ គឺមានសេចក្តីស្ងប់ ទើបមានសេចក្តីសុខ ។

«ការលះការឈ្នះការចាញ់»នេះ បើនិយាយតាមផ្លូវលោកវិញមានន័យសេចក្តីថា សុខចិត្តអនុវត្តតាមរបបប្រជាធិបតេយ្យ គឺឈ្នះក្តីចាញ់ក្តី សុខចិត្តទទួលយកលទ្ធផលដែលមានភាពត្រឹមត្រូវតាមរបបប្រជាធិបតេយ្យនោះ ។ បានសេចក្តីថា តាមរបបប្រជាធិបតេយ្យ ដើម្បីជ្រើសរើសអ្នកដឹកនាំរដ្ឋ គេត្រូវប្រើសន្លឹកឆ្នោត ដែលប្រជាពលរដ្ឋបានបោះដោយសេរីនិងយុត្តិធម៌ ។ ហើយការបោះនោះមានភាពត្រឹមត្រូវហើយ ក៏ទទួលយក ទោះបីឈ្នះក្តីចាញ់ក្តី ។ ការសុខចិត្តឈ្នះសុខចិត្តចាញ់តាមរបបប្រជាធិបតេយ្យនេះ បានលទ្ធផលមកវិញ គឺការស្ងប់ផ្លូវចិត្ត រមែងដេកជាសុខផង ពុំមានសត្រូវជាមួយអ្នកដទៃផង

ពុទ្ធភាសិតក្នុងប្រធានបទនេះ ជាការបញ្ជាក់នូវភាពខុសគ្នារវាងមនុស្សបុថុជ្ជននិងព្រះអរិយបុគ្គលទាំងឡាយ គឺមនុស្សបុថុជ្ជនតែងតែចង់ឈ្នះចាញ់គ្នាជានិច្ច ទោះបីការឈ្នះចាញ់គ្នានោះពុំប្រកបដោយធម៌ គឺពុំមានយុត្តិធម៌ក៏ដោយ ។ ចំណែកព្រះអរិយបុគ្គលដែលលោកស្ងប់នូវអំពើបាប លោកឃើញទោសការឈ្នះការចាញ់នេះ ទើបព្រះទ័យលោកស្ងប់ពុំឡើងចុះទៅតាមអារម្មណ៍នោះឡើយ ។ នេះជាចិត្តប្រសើររបស់បុគ្គលជាន់ខ្ពស់ ដែលធ្វើឲ្យខ្លួនលោកបានសុខផង ធ្វើឲ្យអ្នកនៅជុំវិញខ្លួនលោកបានសុខផង ។៚

✦ ✦

✦